**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែវិច្ឆិកា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែវិច្ឆិកានេះ ការងារបង្កបង្កើនផលដំណាំរដូវវស្សាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវវស្សាសម្រេចបាន ២ ៩០១ ៦០៥ហ.ត ស្មើនឹង១១១,២១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសផលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែវិច្ឆិកានេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សាបញ្ចប់

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៩២៥ ៨២៨ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៦ ៦២៤ហ.ត ស្មើនឹង០,៥៧% និងដោយគ្រឿងយន្តចំនួន ២ ៩០៩ ២០៤ហ.ត ស្មើនឹង៩៩,៤៣%
- ផ្ទៃដីសាបសម្រេចបានចំនួន ១២ ៣៩២ហ.ត តិចជាងឆ្នាំមុនចំនួន ៣ ៤០១ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៩០១ ៦០៥ហ.ត ស្មើនឹង១១១,២១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត លើសឆ្នាំមុន ៩៤ ៩៨២ហ.ត។

#### ១.២ ការប្រមូលផលស្រូវរដូវវស្សា

ការប្រមូលផលស្រូវសម្រេចចំនួន ១ ៥២៧ ៣៥៤ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៥ ១៨៨ ២៥៣តោន លើសឆ្នាំមុនចំនួន ៨០១ ០៨០តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,៣៩៧តោន/ហ.ត។

#### ១.៣ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ១៧៦ ៤៣៨ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១ ១៧៤ហ.ត ស្មើនឹង០,៦៧% និងដោយគ្រឿងយន្តមានចំនួន ១៧៥ ២៦៤ហ.ត ស្មើនឹង៩៩,៣៣%
- ផ្ទៃដីសាបសម្រេចបានចំនួន ៥ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ១៦៩ ១៣៣ហ.ត ស្មើនឹង៣៦,៥៩% នៃផែនការចំនួន ៤៦២ ២៨០ហ.ត តិចជាងឆ្នាំមុនចំនួន ២៤ ០៧៧ហ.ត។

#### ១.៤ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៤ ៤៥៤ហ.ត ស្មើនឹង១២,៤៦% នៃផែនការចំនួន ៣៥ ៧៦០ហ.ត តិចជាងឆ្នាំមុន ៣ ២៨៨ហ.ត

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១១ ១៣២ហ.ត ស្មើនឹង១២,៣៩% នៃផែនការចំនួន ៨៩ ៨១៥ហ.ត តិចជាងឆ្នាំមុន ១១៤ហ.ត។

**១.៥ ការនាំចេញផលិតផលកសិកម្ម**

**១.៥.១ ការនាំចេញអង្ករ**

- ការនាំចេញអង្ករក្នុងខែវិច្ឆិកា ឆ្នាំ២០២១ មានចំនួន ៧២ ០១០តោន កើនឡើងចំនួន ៧ ២៧០តោន (១១,២៣%) បើធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានចំនួន ៦៤ ៧៤០តោន
- បរិមាណអង្ករនាំចេញក្នុងរយៈពេល១១ខែឆ្នាំ២០២១ មានចំនួន ៥៣២ ១៧៩តោន មានការថយចុះចំនួន ៦៨ ៨៦៦តោន (-១១,៤៦%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល១១ខែឆ្នាំ២០២០ ដែលមានចំនួន ៦០១ ០៤៥តោន
- ក្នុងរយៈពេល១១ខែឆ្នាំ២០២១ បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២២ប្រទេស មានបរិមាណសរុបចំនួន ១៣៤ ៤៣៨តោន (ថយចុះចំនួន ៥៣ ៩៥៨តោន ស្មើនឹង-២៨,៦៦%) ទិសដៅប្រទេសចិន មានបរិមាណសរុបចំនួន ២៦៥ ២៤៤តោន (កើនឡើងចំនួន ៣០ ៣០៤តោន ស្មើនឹង១២,៩០%) ទិសដៅអាស៊ាន ចំនួន ៧ប្រទេស មានបរិមាណសរុបចំនួន ៥៤ ៣៥០តោន (ថយចុះចំនួន ២៣ ៨៥៨តោន ស្មើនឹង-៣០,៥១%) និងទិសដៅដទៃទៀតចំនួន២៤ប្រទេស មានបរិមាណសរុប ៧៨ ១៤៧តោន (ថយចុះចំនួន ២១ ៣១៤តោន ស្មើនឹង -២១,៤៣%)
- ក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៦១ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ៣៩៣ ១៣១តោន ស្មើនឹង៧៣,៨៨% និងក្រុមហ៊ុន៥១ដទៃទៀតបាននាំចេញត្រឹមតែ ១៣៩ ០៤៨តោន ស្មើនឹង២៦,១២%។

**១.៥.២ ការនាំចេញស្រូវ**

ក្នុងរយៈពេល១១ខែឆ្នាំ២០២១ ការនាំចេញស្រូវមានចំនួន ៣ ១២៣ ២៤២តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ៩៨៦ ០៨៥,០២តោន) មានការកើនឡើងចំនួន ១ ៣៤៦ ១៣៥តោន (៧៥,៧៥%) បើធៀបនឹងរយៈពេល១១ខែឆ្នាំ២០២០ ដែលមានចំនួន ១ ៧៧៧ ១០៧តោន។

**១.៥.៣ ការនាំចេញកសិផលផ្សេងៗ**

ក្នុងរយៈពេល១១ខែ ឆ្នាំ២០២១ មានបរិមាណនាំចេញដោយធៀបនឹងរយៈពេល១១ខែ ឆ្នាំ២០២០៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៤៣៨ ១៧១,៦៨តោន (កើនឡើងចំនួន ៩,៥៤%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ៩០០ ៩២០តោន វៀតណាមចំនួន ៤៦៦ ៥៣១,៥៦តោន និងប្រទេសចិនចំនួន ៧០ ៧២០,១២តោន
- ដំឡូងមីស្រស់មានចំនួន ៨៨៧ ៧២០តោន (កើនឡើងចំនួន ៣៣,៦៨%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦២២ ៨៧០តោន និងប្រទេសថៃចំនួន ២៦៤ ៨៥០តោន
- ម្សៅដំឡូងមីមានចំនួន ៣០ ៤៧១,៧៤តោន (កើនឡើងចំនួន ១១%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ២៧ ៨០៧,៦០តោន ប្រទេសថៃចំនួន ១ ៣៧៥,៨០តោន ប្រទេសអ៊ីតាលីចំនួន ៦៩៤,៣៤តោន ប្រទេសបែលហ្ស៊ិកចំនួន ២៧២តោន សហរដ្ឋអាមេរិកចំនួន ១៧០តោន និងប្រទេសណេដឺឡែនចំនួន ១៥២តោន
- កាកសំណល់ដំឡូងមីមានចំនួន ៨ ១៨៥តោន (ថយចុះចំនួន -៣៤,១៥%) នាំចេញទៅប្រទេសចិន
- គ្រាប់ស្វាយចន្ទីមានចំនួន ៩២១ ០៦១,៤៧តោន (កើនឡើងចំនួន ៣២៨,៩៦%) នាំចេញទៅប្រទេសវៀតណាមចំនួន ៩១២ ១៧០តោន ប្រទេសចិនចំនួន ៤ ៥៥២,៦៩តោន ប្រទេសថៃចំនួន ៤ ១៤៥,៤០តោន ប្រទេសឥណ្ឌាចំនួន ៩៨,៦០តោន ប្រទេសជប៉ុនចំនួន ៤៤,១៤តោន ប្រទេសកូរ៉េចំនួន ១៦,៨៨តោន ប្រទេសអារ៉ាប់ចំនួន ១៤,៥១តោន ប្រទេសណេដឺឡែនចំនួន ៨,២១តោន ប្រទេសបង់ក្លាដែសចំនួន ៧តោន ប្រទេសឡាវចំនួន ៤តោន ប្រទេសស្វីសចំនួន ០,០២តោន ប្រទេសតូហ្គោចំនួន ០,០១តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០១តោន
- គ្រាប់ពោតមានចំនួន ១៧៨ ០៦៩,៣៤តោន (ថយចុះចំនួន -៨,៤៥%) នាំចេញទៅប្រទេសវៀតណាមចំនួន ១៣៤ ៧៣០តោន ប្រទេសថៃចំនួន ៤២ ៣៥០តោន កោះតៃវ៉ាន់ចំនួន ៩២៦,២៩តោន ប្រទេសបង់ក្លាដេសចំនួន ៤២,០៥តោន និងប្រទេសកូរ៉េចំនួន ២១តោន
- គ្រាប់សណ្តែកបាយមានចំនួន ២៦ ១៩២,៣៥តោន (កើនឡើងចំនួន ៣៣០,៨២%) នាំចេញទៅប្រទេសវៀតណាមចំនួន ២៦ ១៧០តោន និងកោះតៃវ៉ាន់ចំនួន ២២,៣៥តោន
- គ្រាប់សណ្តែកសៀងមានចំនួន ៨៨ ១៦៥,០៤តោន (កើនឡើងចំនួន ២៨៣,២៤%) នាំចេញទៅប្រទេសវៀតណាមចំនួន ៦៦ ២៦៥តោន ប្រទេសថៃចំនួន ២១ ៩០០តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០៤តោន

- ផ្លែចេកស្រស់មានចំនួន ៣៩៥ ៨៦៣,៧៨តោន (កើនឡើងចំនួន ៣១,៨៨%) នាំចេញទៅប្រទេសចិនចំនួន ៣៤៩ ៦៥៦,៤១តោន ប្រទេសវៀតណាមចំនួន ៤៥ ១៩៣,៣៧តោន ប្រទេសជប៉ុនចំនួន ៥៣៣,៥២តោន និងប្រទេសសិង្ហបុរីចំនួន ៤៨០,៤៨តោន

- ផ្លែក្រូចថ្លុងមានចំនួន ៣៤ ៩១៨,៤៤តោន (កើនឡើងចំនួន ១១៩,៦១%) នាំចេញទៅប្រទេសថៃចំនួន ៣៤ ៨៥៤តោន និងប្រទេសវៀតណាមចំនួន ៦៤,៤៤តោន

- ផ្លែស្វាយស្រស់មានចំនួន ២២៦ ៥៧៧,៧១តោន (កើនឡើងចំនួន ១៤៩,៥៣%) នាំចេញទៅប្រទេសវៀតណាមចំនួន ១៩៣ ៧២២,៣៧តោន ប្រទេសថៃចំនួន ៣២ ០១៩,២៨តោន ប្រទេសចិនចំនួន ៦៣៨,១៤តោន ប្រទេសកូរ៉េចំនួន ១៣០,៩២តោន ទីក្រុងហុងកុងចំនួន ៥០,៧៨តោន ប្រទេសសិង្ហបុរីចំនួន ១៦,២០តោន និងប្រទេសគុយវ៉ែតចំនួន ០,០១តោន

- ដំណាប់ស្វាយមានចំនួន ១៦ ៧៧៧,៨២តោន (កើនឡើងចំនួន ១៩១,៤៩%) នាំចេញទៅប្រទេសចិនចំនួន ១៣ ២៥៤,៤៦តោន ប្រទេសថៃចំនួន ១ ៤១៥,០៣តោន ប្រទេសហ្វីលីពីនចំនួន ៩៧៥,០៨តោន ប្រទេសវៀតណាមចំនួន ៥៥៩,៣០តោន ប្រទេសជប៉ុនចំនួន ៥២៣,៧០តោន ចក្រភពអង់គ្លេស ២១,១៤តោន ប្រទេសកូរ៉េចំនួន ១៧,៥០តោន សហរដ្ឋអាមេរិកចំនួន ៨,៥៦តោន កោះតៃវ៉ាន់ចំនួន ៣តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,០៥តោន និងប្រទេសរុស្ស៊ីចំនួន ០,០០២តោន

- ទឹកស៊ីរ៉ូស្វាយមានចំនួន ៤ ៨៤៦,៦៣តោន (កើនឡើងចំនួន ៣៥,២៥%) នាំចេញទៅប្រទេសហ្វីលីពីនចំនួន ៤ ៦៩៨,៦៣តោន និងប្រទេសចិនមានចំនួន ១៤៨តោន

- ដូងប្រេងមានចំនួន ៥៥ ៥១៦,៦៩តោន (កើនឡើងចំនួន ៥,៤០%) នាំចេញទៅប្រទេសឥណ្ឌាចំនួន ៤៣ ១៧៦,៦៩តោន និងប្រទេសម៉ាឡេស៊ីចំនួន ១២ ៣៤០តោន

- ម្រេចមានចំនួន ២៧ ៧៣០,០៧តោន (កើនឡើងចំនួន ៤៥៦,៥៣%) នាំចេញទៅប្រទេសវៀតណាមចំនួន ២៦ ៨៨៧,៦៨តោន ប្រទេសអាល្លឺម៉ង់ចំនួន ៤៩៧,៩០តោន ប្រទេសថៃចំនួន ១៨០តោន ប្រទេសបារាំងចំនួន ៤២,០៩តោន ប្រទេសឥណ្ឌាចំនួន ៤២តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ២៥,៣៨តោន កោះតៃវ៉ាន់ចំនួន ១៥,០៤តោន សាធារណរដ្ឋឆេកចំនួន ១២,៨៤តោន ប្រទេសប៉ូឡូញចំនួន ៧,០៩តោន ប្រទេសជប៉ុនចំនួន ៣,៥៥តោន ប្រទេសកូរ៉េចំនួន ៣,២៥តោន ប្រទេសរុស្ស៊ីចំនួន ២,៧៨តោន សហរដ្ឋអាមេរិកចំនួន ២,០២តោន ប្រទេសសិង្ហបុរីចំនួន ១,៩៧តោន ប្រទេសស្វីសចំនួន ១,៦៤តោន ប្រទេសស៊ុយអ៊ែតចំនួន ១,២៩តោន ចក្រភពអង់គ្លេសចំនួន ១,២៤តោន ប្រទេសអូស្ត្រាលីចំនួន ០,៩០តោន ប្រទេសកាណាដាចំនួន ០,៥២តោន ប្រទេសម៉ាឡេស៊ីចំនួន ០,៤០តោន ប្រទេសលីទុយអានីចំនួន ០,២៩តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,១៩តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០១តោន

- ថ្នាំជក់មានចំនួន ៤ ២៩៤,០៥តោន (ថយចុះចំនួន -២៤,៤២%) នាំចេញទៅប្រទេសវៀតណាមចំនួន ៤ ២១២,៨០តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ៥៩,៤២តោន ប្រទេសហុងគ្រីចំនួន ១៩,៨០តោន ប្រទេសបូស្នៀ និងហឺហ្សេហ្គោវីណាចំនួន ១,៩០តោន ប្រទេសចិនចំនួន ០,១០តោន ប្រទេសឥណ្ឌូនេស៊ីចំនួន ០,០២តោន ប្រទេសសិង្ហបុរីចំនួន ០,០១តោន និងប្រទេសអាល្លឺម៉ង់ចំនួន ០,០០១តោន

- បន្លែចម្រុះមានចំនួន ៩៣,០៨តោន (ថយចុះចំនួន -៥,៧៤%) នាំចេញទៅប្រទេសបារាំង

- ម្ទេសស្រស់មានចំនួន ៨៩ ៣៥៧,១២តោន (កើនឡើងចំនួន ៤៣,១៣%) នាំចេញទៅប្រទេសថៃចំនួន ៨៩ ៣៥៧,១២តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០០២តោន

- ម្ទេសក្រៀមមានចំនួន ២ ១៦០,២៣តោន (កើនឡើងចំនួន ២០,០១%) នាំចេញទៅប្រទេសថៃចំនួន ២ ១៦០តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ០,២១តោន ប្រទេសកូរ៉េចំនួន ០,០១តោន និងប្រទេសកាណាដា ចំនួន ០,០១តោន

- ផលិតផលចំនួន ៨៧មុខ ផ្សេងទៀតមានចំនួន ១៧៧ ៤៧៨,៧៨តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១៦០ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៨ ៥៤៦ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩៤ ៤៥៤ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦១ ១៦០ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១៤ ៣១៩ហ.ត ស្មើនឹង៧៨% និងផ្ទៃដីថែទាំចំនួន ៨៩ ៨៤១ហ.ត ស្មើនឹង២២%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូក្នុងខែតុលាមានចំនួន ៣៨ ៨២៤តោន កើនឡើងចំនួន ៤ ៧១៤តោន ស្មើនឹង១៤% ធៀបនឹងខែមុន និងកើនឡើងចំនួន ៣ ៨៨៥តោន ស្មើនឹង១១% ធៀបខែតុលា ឆ្នាំ២០២០

- ផលិតផលឈើកៅស៊ូក្នុងខែតុលាមានចំនួន ៣០៩ម$^{៣}$ មានការថយចុះ ២៧ម$^{៣}$ ស្មើនឹង៨% ធៀបខែមុន។

**២.៣ ការនាំចេញកៅស៊ូ**

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុងខែតុលាមានចំនួន ៣៩ ១២៧តោន កើនឡើងចំនួន ៦ ០១៥តោន ស្មើនឹង១៨,២% ធៀបនឹងខែមុន និងកើនឡើងចំនួន ៦ ១០០តោន ស្មើនឹង១៨% ធៀបខែតុលា ឆ្នាំ២០២០

- បរិមាណបញ្ចេញលក់ឈើកៅស៊ូក្នុងខែតុលាមានចំនួន ៤២២ម៣ មានការកើនឡើងចំនួន ៩៥ម៣ ស្មើនឹង២៩% ធៀបខែមុន។

**២.៤ តម្លៃកៅស៊ូ**

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែតុលា គឺ១ ៦៥០ដុល្លារ/តោន កើនឡើងចំនួន ២១ដុល្លារ/តោន ស្មើនឹង១,៣២% ធៀបនឹងខែមុន និងកើនឡើងចំនួន ២១៥ដុល្លារ/តោន ស្មើនឹង១៥% ធៀបខែតុលា ឆ្នាំ២០២០

- តម្លៃឈើកៅស៊ូលក់មធ្យមក្នុងខែតុលា គឺ៣២៨,៣៤ដុល្លារ/ម៣

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅនឹងចម្ការក្នុងខែតុលា គឺទឹកជ័រ (DRC ១០០%) មានការប្រែប្រួលពី ៥ ៨០០៛/គ.ក្រ ដល់ ៦ ០២៥៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៣៥០៛/គ.ក្រ ដល់ ៣ ៤៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

**៣.១ ការងារព្រៃឈើ**

- បាននិងកំពុងពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១

- ចុះត្រួតពិនិត្យ វាយតម្លៃ និងប្រគល់-ទទួលការរៀបចំដីចម្ការកសិ-រុក្ខកម្ម កូនឈើ និងពូជដំណាំដល់សហគមន៍ព្រៃឈើគោលដៅចំនួន ៨កន្លែងស្ថិតក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនព្រៃឈើជូនអ្នកស្នើសុំចំនួន១នាក់ដែលមានជ័រទឹកសរុបចំនួន ៤០,១២៥តោន

- ធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើក្រុមហ៊ុន សុវណ្ណភូមិ វិនិយោគកសិ-ឧស្សាហកម្ម ស្ថិតនៅខេត្តព្រះវិហារ។

**៣.២ ការងារអភិរក្សសត្វព្រៃ**

- ចុះប្រមូលសំណាកសត្វចៃតឹកកែ និងចៃចេញពីសត្វស្រុក និងសត្វព្រៃសរុបចំនួន ២៥០ក្បាល

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃឆ្ពោះទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញចំនួន៦ច្បាប់មានសត្វស្វាក្តាមសរុបចំនួន ៣ ០៤០ក្បាល

- ចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន១៩ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃដែលមានទីតាំងស្ថិតនៅខេត្តកំពង់ធំ ពោធិ៍សាត់ បាត់ដំបង ក្រចេះ និងខេត្តកណ្តាល។

**៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ**

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាមសរុបចំនួន ១០១ ៦៦៩ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៧ ០៩២ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅបាននិងកំពុងថែរក្សាសត្វព្រៃចំនួន ១ ៦២៩ ក្បាល (បក្សីចំនួន ៥៨ ប្រភេទ ថនិកសត្វចំនួន ៤៣ ប្រភេទ និងល្មូនចំនួន ១៦ ប្រភេទ) សង្គ្រោះសត្វព្រៃថ្មីចំនួន ៧១ក្បាល ព្យាបាលចំនួន ៣២ក្បាល

- ក្រុមល្បាតសហគមន៍ចំនួន ២៦នាក់ដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺៈ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមប្រវែង ៥ ១៦៦ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ០,៦ហ.ត នៅក្នុងតំបន់សួនសត្វ។

**៣.៤ ការងារដាំដើមឈើ**

- ដឹកប្រឡាយការពារចម្ការគ្រញូងនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្មខេត្តកំពង់ធំសរុបប្រវែង ៥០០ម៉ែត្រ

- ចុះសិក្សា និងពិនិត្យទីតាំងដីសម្រាប់បង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើឡើងវិញលើផ្ទៃដីទំហំ៥៦ហ.ត៣៥៥ ក្នុងខេត្តកំពង់ឆ្នាំង

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ៨២២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ៩៤ហ.ត ឡូតិ៍បង្ហាញកសិរុក្ខកម្មទំហំ៤៤ហ.ត ចម្ការឈើដាំទំហំ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដាទំហំ ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ចែកចាយកូនឈើចំនួន ៤៨ ០៦៥ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ២៨ ៧៥៥ដើម និងថ្នាលបណ្តុះកូនឈើទាំង៦ចំនួន ១៩ ៣១០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន៤៨ករណី (ព្រៃឈើចំនួន៤០ករណី សត្វព្រៃចំនួន៣ករណី និងកាប់រានដីព្រៃចំនួន៥ករណី)

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន៖ ឈើអារសរុបចំនួន ៧៩ម៣ (ចំនួន៤០ករណី) ផ្ទៃដីព្រៃឈើបានកាប់រានទំហំ ៣៩៩ហ.ត (ចំនួន៥ករណី៖ ខេត្តស្ទឹងត្រែង១ករណី ក្រចេះ២ករណី និងខេត្តព្រះវិហារ២ករណី) វត្ថុតាងសត្វព្រៃបានចាប់ឃាត់មានចំនួន ៩៨ក្បាល និង៣៩គ.ក្រ (ចំនួន៣ករណី) អនុផលព្រៃឈើ និងសម្ភារមួយចំនួនទៀត។ វត្ថុតាងជាសត្វព្រៃ និងសំណាកសត្វព្រៃបានប្រមូលតាមរយៈការប្រគល់-ទទួលចំនួន៤៨ករណី ធ្វើកិច្ចសន្យា៣ករណី (សត្វព្រៃរស់ចម្រុះប្រភេទចំនួន ៥៤ក្បាល សត្វព្រៃងាប់ចម្រុះប្រភេទចំនួន ៣៣ក្បាល ទ្រូងអណ្តើកសោមចំនួន១ទ្រូង អណ្តើកភ្នំចំនួន១១ទ្រូង អណ្តើកស្រែចំនួន១៨ស្នូក)។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីន១កន្លែងនៅខេត្តស្ទឹងត្រែង និងសំណើសុំពន្យារសុពលភាពរោងម៉ាស៊ីន និងរោងសិប្បកម្ម២កន្លែងនៅខេត្តបាត់ដំបង និងខេត្តមណ្ឌលគិរី

- ក្រុមហ៊ុនចំនួន៣នាំចេញផលិតផលរានទេវតា ឈើកែច្នៃទៅក្រៅប្រទេសចំនួន ៥២ម៣ ជ័រទឹកចំនួន ៨០តោន

- ក្រុមហ៊ុនចំនួន២នាំចូលឈើកែច្នៃមានបរិមាណចំនួន ២១៥ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១មានជ័រទឹកចំនួន ១៦តោន និងផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃចំនួន ២៧៥ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- ប្រមូលចំណូលសរុប ១០១ ១៥០ ២៩០រៀល និង១ ៨៧៦,៩៨ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្តូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។ កំពុងរៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ការសាងសង់ឡជីវឧស្ម័នក្នុងខែវិច្ឆិកា ឆ្នាំ២០២១ នេះសម្រាប់កម្មវិធី NBP សាងសង់ឡបានចំនួន ២៧ឡ ក្នុងខេត្តគោលដៅ១៤ខេត្ត។

### ៤.២ ការងារសុខភាពសត្វ

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៣៨ករណី ក្នុងនោះ ត្រួតពិនិត្យ

មានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន៣៨ករណី (ការដឹកជញ្ជូនជ្រូករស់២៨ករណី និងការដឹកជញ្ជូនមាន់រស់១០ករណី)។ រាជធានី-ខេត្តចំនួន ២៤បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៧ ៤៥៨លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

- **ការងារផ្សព្វផ្សាយបច្ចេកទេស**

ចូលរួមសហការរៀបចំសៀវភៅចិញ្ចឹមមាន់មេពូជ និងរៀបចំឯកសារផ្សព្វផ្សាយស្តីពីជំងឺប៉េស្តជ្រូកអាហ្វ្រិកនៅស្រុកត្រាំកក់ ខេត្តតាកែវក្រោមការគាំទ្ររបស់អង្គការ FAO។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៦ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ២ ១៣៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តបានចំនួន ៤០០តោន សរុបរយៈពេល១១ខែចំនួន ១ ៧៣០តោន ស្មើនឹង១៥,៧៣% នៃផែនការចំនួន ១១ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ៦៧០តោន

- នេសាទគ្រួសារដែននេសាទបានចំនួន ១៥ ២០០តោន សរុបរយៈពេល១១ខែចំនួន ២១៣ ០០០តោន ស្មើនឹង ៧១% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ២២ ៥០០តោន

- នេសាទគ្រួសារតាមវាលស្រែបានចំនួន ១២ ៧០០តោន សរុបរយៈពេល១១ខែចំនួន ៦០ ៣០០តោន ស្មើនឹង ៤៣,០៧% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ៤៣ ៤០០តោន។

#### ៥.១.២ នេសាទសមុទ្រ

បានចំនួន ១២ ៦០០តោន សរុបរយៈពេល១១ខែចំនួន ១១២ ០០០តោន ស្មើនឹង៨៦,១៥% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ កើនឡើងចំនួន ១០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាបានចំនួន ១ ៤៥៦តោន សរុបរយៈពេល១១ខែចំនួន ២២៩ ០៥៥តោន ស្មើនឹង៤៧,៦២% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ១៥៨ ៩៤៥តោន

- ការចិញ្ចឹមក្រពើបានចំនួន ១៨ ៣០០ក្បាល សរុបរយៈពេល១១ខែចំនួន ២៧១ ១០០ក្បាល ស្មើនឹង៨២,១៥% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ៣៤ ៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជបានចំនួន ៤០០ ០០០កូន សរុបរយៈពេល១១ខែចំនួន ៣២៣ ៨០៦ ០០០កូន ស្មើនឹង ១១៩,៩៣% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ១១៥ ១០៦ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបបានចំនួន ៣ ៧០០តោន សរុបរយៈពេល១១ខែចំនួន ៤៦ ១៥០តោន ស្មើនឹង៥៧,៦៩% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ៣ ១០០តោន

- ផលនេសាទសមុទ្របានចំនួន ១ ១០០តោន សរុបរយៈពេល១១ខែចំនួន ១០ ៦៦០តោន ស្មើនឹង៨៨,៨៣% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ កើនឡើងចំនួន ១០តោន

- ការផលិតទឹកត្រីបានចំនួន ៥ ៣០០ ០០០លីត្រ សរុបរយៈពេល១១ខែចំនួន ៤៩ ៥០០ ០០០លីត្រ ស្មើនឹង ៩០% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ២ ៥០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១០៤ករណី ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ៤ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១០៤ករណី និងសមុទ្រចំនួន ០ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ៣៩តោន សរុបរយៈពេល១១ខែចំនួន ២ ៩១៦តោន ស្មើនឹង៣៦,៤៥% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ កើនឡើងចំនួន ៩៧១តោន

- ផលនេសាទកែច្នៃនាំចេញពុំមាន សរុបរយៈពេល១១ខែចំនួន ១៥០តោន ស្មើនឹង៧,៥០% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ៨៤តោន។

### ៥.៦ ការប្រមូលថវិកាសេវាជលផល

- ចំណូលចំនួន ៥ ៩៧១ ២០០រៀល សរុបរយៈពេល១១ខែចំនួន ៥៣៦ ៨៦៣ ៦២៨រៀល ស្មើនឹង១៤៩,៧១% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបខែវិច្ឆិកា ឆ្នាំ២០២០ ថយចុះចំនួន ៣៣ ៤៧៧ ៦៤២រៀល។

## ៦ ផ្នែកអធិការដ្ឋាន

- ការទទួលពាក្យបណ្តឹងតាមរយៈប្រអប់សំបុត្រ និងតាមរយៈប្រព័ន្ធអ៊ិនធើណេតពុំមាន

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៩៥ករណី លើវិស័យព្រៃឈើ១៤ករណី ជលផល២៧ករណី សុខភាពសត្វនិងផលិតកម្មសត្វ១២ករណី កៅស៊ូ១ករណី ក្សេត្រសាស្ត្រ១ករណី នីតិកម្ម២ករណី និងវិស័យផ្សេងៗ៣៨ករណី

- ចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៥ករណី។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៦៥៦ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៥៤ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២៦៦ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៣៦ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ០០២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ២៩ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២៧ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស ខែវិច្ឆិកា និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨១០នាក់ (ស្រី១ ៤១២នាក់ ស្មើនឹង២៤,៣០%) រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១៤នាក់ (ស្រី៨២៤នាក់ ស្មើនឹង២៨,២៧%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៨៩៦នាក់ (ស្រី៥៨៨នាក់ ស្មើនឹង២០,៣០%)
- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៩នាក់
- រៀបចំប្រកាសស្តីពីការទទួលស្គាល់មន្ត្រីរាជការផ្ទេរមកពីក្រសួងក្រៅក្រសួងចំនួន ៣នាក់
- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារ ចំនួន៧នាក់ (ស្រី៦នាក់) ក្នុងនោះមាន៖ ច្បាប់ឈប់សម្រាកលំហែមាតុភាព ចំនួន៥នាក់ និងច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ចំនួន២នាក់ (ស្រី១នាក់)
- រៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ចំនួន៣នាក់

- រៀបចំការដំឡើងឋានន្តរសក្តិ និងថ្នាក់ប្រចាំឆ្នាំ២០២២
- រៀបចំការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១០២នាក់ (ស្រី២៨នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ៩២នាក់ (ស្រី២៥នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលខ្លី និងមធ្យមតាមរយៈប្រព័ន្ធ online ចំនួន ១០នាក់ (ស្រី៣នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣
- ពិនិត្យ និងកែសម្រួលគោលនយោបាយអភិវឌ្ឍន៍កសិកម្មឆ្នាំ២០២១-២០៣០
- រៀបចំ និងពិនិត្យលើគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័នឆ្នាំ២០២១-២០៣០
- រៀបចំ និងពិនិត្យលើសំណើសុំអនុញ្ញាតជាគោលការណ៍ប្រើប្រាស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣១
- រៀបចំរបាយការណ៍លទ្ធផលកិច្ចប្រជុំពិនិត្យ និងពិគ្រោះយោបល់លើរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (IDP) ឆ្នាំ២០១៥-២០២៥
- រៀបចំលើសំណើសុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជាឆ្នាំ២០២១-២០៣០
- ចុះតាមដានការងារបង្កបង្កើនផល និងធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សាឆ្នាំ២០២១-២០២២សហការជាមួយមន្ត្រីស្ថិតិ ថ្នាក់ខេត្ត ស្រុក នៅខេត្តក្រចេះ និងខេត្តប៉ៃលិន
- ចុះសិក្សាស្ថានភាពផលិតផល និងទីផ្សារកសិកម្ម នៅខេត្តព្រះវិហារ ឧត្តរមានជ័យ សៀមរាប មណ្ឌលគិរី និងខេត្តកំពង់ចាម
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលនៅតាមបណ្តារាជធានី-ខេត្តទាំង២៥។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- ចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ១ ៩១០លានរៀល
- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៦ ៣០៣លានរៀល
- រៀបចំសំណើសុំថវិកាចំនួន ៤ ៣៤៥ ៥១៤ ៩០០រៀល ដើម្បីបំពេញឡើងវិញចូលគណនីរបស់កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (CAPFISH-Capture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់សហភាពអឺរ៉ុប
- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០២០ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មខេត្តកណ្តាល និងវិទ្យាស្ថានជាតិកសិកម្មខេត្តកំពង់ចាម
- ទទួលឥណទានធានាចំណាយចំនួន៧គម្រោង និងបានរៀបចំឯកសារសុំសម្រាប់ដេញថ្លៃដើម្បីដំណើរការអនុវត្តនូវកិច្ចលទ្ធកម្ម
- ចូលរួមប្រជុំផ្ទៃក្នុងករណីការដោះដូរទីតាំងដីការិយាល័យកសិកម្មស្រុកព្រះស្តេចនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង
- ចូលរួមប្រជុំផ្ទៃក្នុងករណីការលក់ក្រពើរដ្ឋដែលស្ថិតនៅក្រោមការគ្រប់គ្រង កត់ត្រាស្ថិតិរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប ដើម្បីបង្វែរចូលថវិកាជាតិ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង២០២១-២០២៣

- រៀបចំផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤
- រៀបចំផែនការវដ្ដទេយ្យបុរេប្រទានឆ្នាំ២០២១
- រៀបចំផែនការវិចារណកម្មចំណាយលើលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការថវិកាឆ្នាំ២០២២
- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ទទួលជួបពិភាក្សាការងារជាមួយស្ថានទូត៣លើក
- ចូលរួមកិច្ចប្រជុំ២លើក និងទិវា១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ចូលរួមកិច្ចប្រជុំ២លើក (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស
- ចូលរួមសិក្ខាសាលា (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ២លើកក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស
- សម្របសម្រួលកិច្ចប្រជុំ៧លើក ទិវា២លើកលើការងារក្នុងប្រទេស
- សម្របសម្រួលលើសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសហប្រតិបត្តិការអាស៊ានលើការងារវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍
- សម្របសម្រួលលើសំណើសុំផ្តល់លិខិតតុបករណ៍បញ្ជាក់ការទទួលស្គាល់ពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបុក៣ស្តីពីការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់
- សម្របសម្រួលកិច្ចការងារជាមួយអង្គការ Oxfam ស្តីពីកម្មវិធីអភិបាលកិច្ចធនធានធម្មជាតិ និងកម្មវិធីសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន
- សម្របសម្រួលកិច្ចការងារជាមួយអង្គការគោសប្បុរសស្តីពីកម្មវិធីសង្គ្រោះ និងថែរក្សាសត្វព្រៃ។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣៣ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៣ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ និងវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ៣ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨ក្រុមហ៊ុន សរុបចំនួន ៥៨សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- ពិនិត្យ និងផ្តល់មតិលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំនៅកម្ពុជា
- ពិនិត្យនិងផ្តល់មតិលើសំណើរសុំគោលការណ៍ផ្សព្វផ្សាយធ្វើសិក្ខាសាលាបណ្តុះបណ្តាលដល់អាជីវករលក់សម្ភារកសិកម្ម និងកសិករអំពីរបៀបប្រើប្រាស់ផលិតផលជីកសិកម្មប្រកបដោយសុវត្ថិភាពខ្ពស់តាមរយៈស្ថានីយវិទ្យុ និងទូរទស្សន៍នៅតាមបណ្តារាជធានី-ខេត្ត។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤ក្រុមហ៊ុន
- ចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ៣ខេត្ត។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ថែទាំគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន១៧ និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តលើគេហទំព័រសរុបចំនួនផុស ២៦២ព័ត៌មាន
- ធ្វើការតាមដាន និងតំហែទាំប្រព័ន្ធបណ្ដាញអ៊ីនធើណេត និងម៉ាស៊ីនមេនៅក្នុងមជ្ឈមណ្ឌលឲ្យដំណើរការល្អ
- បន្តចុះប្រមូលទិន្នន័យដំណាំសក្ដានុពលក្នុងខេត្តកំពង់ធំ នៅក្នុងស្រុកសន្ទុក ដើម្បីរៀបចំជាផែនទីដំណាំកសិកម្ម
- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្ដី ដែលទទួលបានពីរដ្ឋបាល និងផ្នែកផ្សេងៗសរុបចំនួន ២០ក្បាល/ច្បាប់
- បញ្ចូលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម និងអត្ថបទផ្សេងៗសរុបចំនួន ២១ក្បាល/ច្បាប់ ព្រឹត្តបត្រព័ត៌មានចំនួន៤ និងវីដេអូបច្ចេកទេសចំនួន ៦វីដេអូលើគេហទំព័បណ្ណាល័យអេឡិចត្រូនិក។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះទៅថត និងផលិត video បទយកការណ៍ស្ដីពីមុខរបរចិញ្ចឹមមាន់ស្រែយកកូនលក់ បទពិសោធន៍ជោគជ័យលើការចិញ្ចឹម និងបង្កាត់ពូជមាន់ខ្មៅ
- ចាក់ផ្សាយឡើងវិញស្ដីពីវេទិកាស្វែងយល់ពីកសិកម្មចំនួន ២ប្រធានបទ
- ចាក់ផ្សាយឡើងវិញស្ដីពីនាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ
- បញ្ចូលអត្ថបទបច្ចេកទេសកសិកម្មស្ដីពីបច្ចេកទេសស្ដីពីពូជស្រូវស្រាលក្រអូប បច្ចេកទេសដាំដំណាំខាត់ណា-ដើម ស្លឹកខ្ទឹម និងការចិញ្ចឹមពពែ
- ជួយដោះស្រាយបញ្ហា និងផ្ដល់ព័ត៌មានបច្ចេកទេសកសិកម្មនានាដល់កសិករ និងអតិថិជនចំនួន ៧សំណួរ/ចម្លើយ គឺខេត្តត្បូងឃ្មុំ រតនគិរី ពោធិ៍សាត់ កំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់អំពីក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃផែនការសកម្មភាពពហុវិស័យស្ដីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជា
- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មនៅខេត្តៈ បន្ទាយមានជ័យចំនួន ៤កិច្ចសន្យា កំពង់ឆ្នាំងចំនួន ២៦កិច្ចសន្យា កំពង់ស្ពឺចំនួន ៤៥៨កិច្ចសន្យា កំពង់ធំចំនួន ១២កិច្ចសន្យា ក្រចេះចំនួន ៤កិច្ចសន្យា មណ្ឌលគិរីចំនួន ៨កិច្ចសន្យា ព្រៃវែងចំនួន ១កិច្ចសន្យា សៀមរាបចំនួន ២កិច្ចសន្យា ព្រះសីហនុចំនួន ១៩កិច្ចសន្យា ស្ទឹងត្រែងចំនួន ៧២កិច្ចសន្យា ស្វាយរៀងចំនួន ១កិច្ចសន្យា ប៉ៃលិនចំនួន ១០កិច្ចសន្យា ឧត្តរមានជ័យចំនួន ៤កិច្ចសន្យា ត្បូងឃ្មុំចំនួន ៥កិច្ចសន្យា សរុបចំនួន ៦២៦កិច្ចសន្យា
- ចុះផ្សព្វផ្សាយ សិក្សា និងប្រមូលផលទិន្នន័យបឋមអំពីការយល់ដឹង និងការអនុវត្តផលិតផលកសិកម្មតាមកិច្ចសន្យានៅខេត្តមណ្ឌលគិរី
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាមួយមន្ទីរកសិកម្ម ក្រុមហ៊ុនវិនិយោគកសិកម្ម និងសហគមន៍កសិកម្ម ដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការសិក្សាស្រាវជ្រាវស្ដីពីគំរូធុរៈកិច្ចវិនិយោគកសិកម្មប្រកបដោយបរិយាប័ន្ននៅក្នុងខេត្តមណ្ឌលគិរី និងខេត្តព្រះវិហា
- ចុះសិក្សាជាមួយវិស័យឯកជនលើតម្រូវការ និងផ្គត់ផ្គង់ទីផ្សានៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី
- ចុះទស្សនកិច្ចសិក្សាលើកសិធុរៈកិច្ចខ្នាតតូច និងមធ្យមនៅសហគមន៍កសិកម្មទឹកហូតមានជ័យក្ដីសង្ឃឹមខេត្តកំពង់ឆ្នាំង
- ចុះសិក្ខាសាលាផ្សព្វផ្សាយស្ដីពីលិខិតដ្ឋានគតិយុត្ត និងគោលការណ៍ពាក់ព័ន្ធនឹងផលិតផលកសិកម្មតាមកិច្ចសន្យានៅខេត្តតាកែវ
- ចុះសិក្ខាសាលាផ្សព្វផ្សាយស្ដីពីការជំរុញការនាំចេញផលិតកម្មកសិកម្មតាមរយៈការពង្រឹងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយក្រុមហ៊ុន រោងចក្រ សហគ្រាសនៅខេត្តកំពង់ឆ្នាំង

- ចុះសិក្ខាសាលាផ្សព្វផ្សាយស្តីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូចទៅទីផ្សារតាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តព្រៃវែង
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសក្រោយការប្រមូលផលនៃផលិតកម្មកសិកម្មនៅខេត្តបាត់ដំបង
- ចុះសិក្ខាសាលាផ្សព្វផ្សាយស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តត្បូងឃ្មុំ
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តកំពង់ធំ
- ចុះបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតកម្មកសិកម្មនៅខេត្តក្រចេះ
- ចុះសិក្សាគុណភាពគ្រាប់ស្វាយចន្ទីស្រស់នៅខេត្តព្រះវិហារ និងខេត្តត្បូងឃ្មុំ ដើម្បីរៀបចំសេចក្តីព្រាងស្តង់ដារគ្រាប់ស្វាយចន្ទីស្រស់។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមកិច្ចប្រជុំពិនិត្យលើទម្រង់ (Outline) ផែនការមេទំនើបកម្មវិស័យកសិកម្មកម្ពុជា-ចិន
- ចូលរួមកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្ស និងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាតាមរយៈប្រព័ន្ធ Online
- ចុះប្រមូលព័ត៌មានកសិករ និងរៀបចំទិវាចម្ការពិសោធន៍បង្ហាញដំណាំសណ្តែកដីនៅខេត្តកំពង់ស្ពឺ
- ចុះប្រមូលសំណាកសមាសភាពចង្រៃលើដំណាំនៅខេត្តកំពង់ស្ពឺ និងខេត្តព្រះវិហារ
- ចុះប្រមូលទិន្នន័យពិសោធន៍ និងបង្ហាញពីបច្ចេកទេសក្រោយការប្រមូលផលនៅខេត្តពោធិ៍សាត់ និងបន្ទាយមានជ័យ
- ចុះធ្វើទិវាស្រែបង្ហាញផលិតកម្មដំណាំស្រូវនៅខេត្តតាកែវ
- ចុះសម្ភាសន៍កសិករអំពីការគ្រប់គ្រងស្មៅចង្រៃលើដំណាំស្រូវនៅខេត្តព្រៃវែង
- ចុះធ្វើពិសោធន៍វាយតម្លៃលើដំណាំដំឡូងផ្វានៅខេត្តព្រះវិហារ
- ចុះត្រួតពិនិត្យការងារពិសោធន៍ បើកវគ្គបណ្តុះបណ្តាល និងរៀបចំទិវាស្រែបង្ហាញនៅខេត្តសៀមរាប
- ចុះពិនិត្យការងារពិសោធន៍ និងការងារផលិតកម្មនៅស្ថានីយស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍នៅខេត្តព្រះវិហារ
- ចុះត្រួតពិនិត្យ និងវាយតម្លៃពិសោធន៍នៅខេត្តកំពង់ស្ពឺ និងខេត្តព្រះវិហារ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- គ្រប់មហាវិទ្យាល័យបានដំណើរការ កម្មវិធីការពារនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រ
- ទទួលបេសកកម្មធនាគារពិភពលោកចុះពិនិត្យវាយតម្លៃលើការអនុវត្តគម្រោង Higher Education Improvement Project (HEIP)
- រៀបចំពិធីសំណេះសំណាលនិងជូនដំណើរនិស្សិតចំនួន២០០នាក់ ទៅបំពេញការហាត់ការ រយៈពេល១១ខែ នៅប្រទេសអ៊ីស្រាអែល
- ចូលរួមសិក្ខាសាលាស្តីពី Inter University Policy Dialogue រៀបចំឡើងដោយសាកលវិទ្យាល័យអប់រំហុងកុង
- មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) បានចុះ MOU ជាមួយនឹងធនាគារប្រៃសណីយ៍កម្ពុជា ក.អ (Post Bank PLC) លើការសហការគម្រោងឡជីវឧស្ម័នក្រោមកិច្ចគាំទ្ររបស់អង្គការយូនីដូ
- ចូលរួមវគ្គបណ្តុះបណ្តាលតាមរយៈប្រព័ន្ធអនឡាញ ស្តីអំពីCommemorative Symposium on One Health for the Completion of OIE VET Twining Project ជាមួយប្រទេសជប៉ុន
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំប្លង់មេរៀនមុខវិជ្ជាចំនួន ៥ (Veterinary Biochemistry and Molecular Biology, Introduction to Veterinary Science, Animal Nutrition, Animal Genetic, Veterinary Communication and Culture)។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ១ ១២៧នាក់ (ស្រី៤៦៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងសៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធចិញ្ចឹមគោទឹកដោះ ការពិសោធចិញ្ចឹមបង្គា ការពិសោធបង្កាត់ពូជមាន់ ការសិក្សាពិសោធថ្នាំបណ្តេញសត្វល្អិត ការពិសោធចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់កេសរកូល ការពិសោធដំណាំព្រីង ការសិក្សាពិសោធផលិតម្សៅឬស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងប្រវាក់តម្លៃស្វាយចន្ទី

- ចូលរួមសិក្ខាសាលាស្តីពី Production, Aplication and Demonstration of Eco-friendly Fertilizer for Developing Countries តាម Online នៅសាកលវិទ្យាល័យកសិកម្មប្រទេសចិន

- ចូលរួមសន្និសីទថ្នាក់ជាតិស្តីពីអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិតាមប្រព័ន្ធ Online

- ចូលរួមក្នុងកិច្ចពិភាក្សាស្តីពីការរៀបចំកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតជំនាញកសិកម្មនិងអភិវឌ្ឍន៍ជនបទ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វនៅរាជបណ្ឌិត្យសភា

- ចូលរួមប្រជុំពិគ្រោះយោបល់សេចក្តីព្រាងស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៦១០នាក់ (ស្រី២៧៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ត្រៀមការពារសារណាបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មផ្នែកអាហារូបករណ៍ជំនាន់ទី១៥ និងផ្នែកបណ្តុះបណ្តាលបន្តជំនាន់ទី១៨

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- ធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- ធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- ចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍កូន (ទិន្នផលជ័រ) សរុបចំនួន១២ចម្ការពិសោធន៍

- ថែទាំច្បារពូជកៅស៊ូសម្រាប់បម្រើដល់ការពិសោធស្រាវជ្រាវ និងដាំពង្រីកកូនកៅស៊ូចំនួន៧៧៩កូននៅក្នុងច្បារពូជ

- ត្រួតពិនិត្យចម្ការបង្ហាញនៅខេត្តមណ្ឌលគិរីស្តីពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ ដោយមានការសហការជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងអង្គការ WWF-កម្ពុជា

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ និងស្រង់ទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នា ដើម្បីលាបរំញោចតាមពិធីសាពិសោធន៍

- យកសំណាក និងវិភាគសរីរសាស្ត្រទឹកជ័រ (LD) ចម្ការពិសោធន៍ចំនួន១១ ស្មើនឹង ៣៩៦សំណាក

- ថែទាំកូនកៅស៊ូនៅថ្នាលបណ្តុះកូនឆ្នាំ២០២១-២០២២

- ត្រួតពិនិត្យការប្រមូលផលទឹកជ័រនៅចម្ការពិសោធន៍

- ត្រួតពិនិត្យការងារបច្ចេកទេសចៀរជ័រ និងប្រមូលផលទឹកជ័រកៅស៊ូតាមរាននីមួយៗ
- ត្រួតពិនិត្យការធ្វើជំរឿនដើមកៅស៊ូដើម្បីរៀបចំរានចៀរជ័រនៅក្នុងឆ្នាំ២០២២
- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) សរុបចំនួន ៦សំណាកដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដា CS។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ៩០១ ៦០៥ហ.ត ស្មើនឹង១១១,២១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត និងការប្រមូលផលស្រូវវស្សាសម្រេចចំនួន ១ ៥២៧ ៣៥៤ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៥ ១៨៨ ២៥៣តោន លើសឆ្នាំមុនចំនួន ៨០១ ០៨០តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,៣៩៧តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវប្រាំង
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរ

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្កុរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

### ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្ដែង រួមទាំងការរៀបចំវគ្គបណ្ដុះបណ្ដាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃ ពុធ ៤ កើត ខែ ពិសាខ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**